**មាត្រា ៥** : ថ្លៃអាករលើការពន្យារពេលប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ត្រូវកំណត់ចំនួនប្រាំសែនរៀល ( ៥០០.០០០៛,០០ ) ។

**មាត្រា ៦** : ថ្លៃអាករគ្រប់ប្រភេទខាងលើនេះ ត្រូវបង់ចូលថវិកាជាតិ ។

បែបបទ នៃការប្រមូលអាករនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងមហាផ្ទៃ ។

**មាត្រា ៧** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ គ្រប់ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| --- | --- |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៦

# អនុក្រឹត្យលេខ ៣០ អនក្រ.បក

# ស្តីពីបែបបទសំរាប់អនុវត្តចំពោះការអនុញ្ញាតអោយជនបរទេសអន្តោប្រវេសន្តចេញ ចូល និង ស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋ មន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២

- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋា ភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ នស- ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស.រកត - ១០៩៤ - ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត - ១០៩៤- ៩០ -៨៣ ចុះថ្ងៃ ទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស.រកត - ០១៩៦ - ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ
- បានឃើញ ច្បាប់ ស្តីពីអន្តោប្រវេសន្ត ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០៥ ន/ស ៩៤ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យ លេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីកាវៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តាមការយល់ព្រម នៃគណៈរដ្ឋមន្ត្រី

**សំរេច**

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា ១** : ជនបរទេសអន្តោប្រវេសន្ត គឺជនបរទេសណាដែលបានកំណត់ក្នុងជំពូកទី៣ នៃច្បាប់ ស្តីពី អន្តោប្រវេសន៍ ។

**មាត្រា ២ :** អនុក្រឹត្យនេះកំណត់ពីបែបបទ សំរាប់ការអនុញ្ញាតអោយជនបរទេសអន្តោប្រវេសន្ត ចេញ ចូល និងស្នាក់អាស្រ័យ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២

## បែបបទក្នុងការសុំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា

**មាត្រា ៣ :** ជនបរទេសដែលមានបំណងមកស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាជនបរទេសអន្តោប្រវេសន្ត អាចដាក់ពាក្យសុំបានមកក្រសួងមហាផ្ទៃ តែតាមរយៈអាជ្ញាធរទូត ឬកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ឬតែតាមរយៈអាជ្ញាធរបរទេសណាមួយដែលតំណាងអោយផលប្រយោជន៍ នៃព្រះរាជាណាចក្រកម្ពុជា នៅក្រៅប្រទេសដោយ ÷

១–ត្រូវបំពេញបែបបទ ទិដ្ឋាការ ។

២–ត្រូវភ្ជាប់មកជាមួយនូវសេចក្តីចំលងលិខិតឆ្លងដែនរបស់ខ្លួន ឬ សេចក្តីចំលងឯកសារធ្វើ ដំណើរណាមួយដែលមានតម្លៃស្មើគ្នា ដែលមានសុពលភាពយ៉ាងតិច ៦ខែ មុនថ្ងៃចូល ព្រះរាជាណាចក្រកម្ពុជា ។

៣-ត្រូវមានរូបថតទំហំ ៤ × ៦ ចំនួន ៣សន្លឹក « ថតចំពីមុខ គ្មានពាក់មួក និងមិនពាក់វ៉ែន តា ពណ៌ ។

៤–ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់សុខភាព ចំនួនមួយច្បាប់ ដែលចេញអោយដោយវេជ្ជបណ្ឌិត នៃប្រទេសដើមរបស់ខ្លួន ។ វិញ្ញាបនប័ត្រនេះត្រូវមានកាលបរិច្ឆេទ មិនហួសពី៣ខែ នៅពេលដាក់ពាក្យ ។

៥–ត្រូវមានភស្តុតាងបញ្ជាក់អំពីការមានមធ្យោបាយគ្រប់គ្រាន់សំរាប់ចិញ្ចឹមជីវិតផ្ទាល់ខ្លួន និង សមាជិកក្នុងបន្ទុកខ្លួនបាន និងមានអ្នកធានាក្នុងស្រុក ដែលមានសមត្ថភាព និង លទ្ធភាពទទួលខុសត្រូវខាងជីវភាព និងមធ្យោបាយ ផ្គត់ផ្គង់ផ្សេងៗទៀត ។

៦–ត្រូវមានលិខិតថ្កោលទោស ដែលចេញអោយដោយអាជ្ញាធរមានសមត្ថកិច្ច នៃប្រទេសដើម របស់ខ្លួន ។

៧–ត្រូវមានសេចក្តីចម្លងកិច្ចសន្យាការងារជាមួយឯកជន ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជាមួយច្បាប់ បើសិនជាមាន ។

៨–ត្រូវមានសលាកប័ត្រ ស្តីពីការតម្កល់ប្រាក់ធានាសំរាប់ថ្លៃសោហ៊ុយធ្វើដំណើរត្រឡប់ទៅវិញ ឬមាតុភូមិនិវត្តន៍ ជាយថាហេតុចំពោះ ÷

ក–ជនបរទេសដែលមកពីប្រទេស ដែលមានព្រំប្រទល់ជាប់នឹងព្រះរាជាណាចក្រកម្ពុជា ចំនួន ប្រាំសែនរៀល ( ៥០០.០០០៛០០ ) ។

ខ–ជនបរទេស ដែលមកពីអាស៊ី និង អូសេអានី ចំនួន មួយលានពីរសែនប្រាំម៉ឺនរៀល (១.២៥០.០០០៛០០ )

គ–ជនបរទេស ដែលមកពីមជ្ឈិមបូព៌ា និង អាហ្វ្រិក ចំនួន ពីរលានប្រាំសែនរៀល (២.៥០០.០០០ ៛០០ )

ឃ–ជនបរទេស ដែលមកពីអឺរ៉ុប និង អាមេរិក ចំនួន បីលានប្រាំពីរសែនប្រាំម៉ឺនរៀល (៣.៧៥០.០០០ ៛០០ )

ប្រាក់នេះត្រូវតម្កល់នៅធនាគារជាតិនៃកម្ពុជា ហើយអាចដកវិញបានលុះណាតែមានការ អនុញ្ញាតពីក្រសួងមហាផ្ទៃ ។

ជនបរទេសដែលមានសហព័ទ្ធ ឬកូនជាអនីតិជន អាយុតិចជាង ១៨ ឆ្នាំ មានបំណងស្នើសុំជាជនបរទេសអន្តោប្រវេសន្តអាចធ្វើពាក្យស្នើសុំនោះជាចង្កោមគ្រួសារ ។

ក្នុងករណីពាក្យស្នើសុំនោះបានទទួលការយល់ព្រម សាមីជនត្រូវបង់ថ្លៃអាករទិដ្ឋាការចំនួន ពីរសែនប្រាំម៉ឺនរៀល(២៥០.០០០៛០០)ក្នុងសមាជិកគ្រួសារម្នាក់ៗ លើកលែងតែកុមារអាយុ ១២ ឆ្នាំចុះ ត្រូវបង់ចំនួន មួយសែនពីរម៉ឺនប្រាំពាន់រៀល ( ១២៥.០០០៛០០ ) ក្នុងកុមារម្នាក់ៗ ។

**មាត្រា ៤** : អនីតិជន សហព័ទ្ធដែលរួមរស់ជាមួយគ្នា និង អាស្រ័យពឹងពាក់គ្នាខាងផ្លូវកាយ និងខាងហិរញ្ញវត្ថុ ក្នុងលក្ខណៈជាសមាជិកគ្រួសារយ៉ាងជិតស្និទ្ធ ក៏អាចត្រូវទទួលបានការអនុញ្ញាតអោយធ្វើ អន្តោប្រវេសន្តបានដែរ នៅពេលដែល

ជនបរទេសអន្តោប្រវេសន្តណាមួយត្រូវបានទទួល ស្គាល់ហើយនោះ ។

**មាត្រា ៥ :** ការទទួលស្គាល់ជនបរទេសណាមួយជាជនអន្តោប្រវេសន្ត ត្រូវសំរេចដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ។

## ជំពូកទី៣

## ការស្នាក់នៅ ការងារ និង ការចេញ ចូល

**មាត្រា ៦ :** ជនបរទេសដែលត្រូវបានទទួលស្គាល់ ជាជនបរទេសអន្តោប្រវេសន្ត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវសុំប័ណ្ណស្នាក់នៅ នៅការិយាល័យជនបរទេស នៃស្នងការដ្ឋាននគរ បាលខេត្ត ក្រុង ក្នុងរយៈពេល៤៨ម៉ោង បន្ទាប់ពីបានមកដល់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៧ :** ជនបរទេសអន្តោប្រវេសន្ត ត្រូវសុំប័ណ្ណការងារតាមការកំណត់នៃច្បាប់ការងាររបស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨ :** ជនបរទេសអន្តោប្រវេសន្ត ដែលមានបំណងចាកចេញពី ព្រះរាជាណាចក្រកម្ពុជា ជាបណ្តោះ អាសន្នត្រូវសុំការអនុញ្ញាតពីក្រសួងមហាផ្ទៃ ។ បែបបទនៃការស្នើសុំមានដូចតទៅ ÷

១- ត្រូវបំពេញពាក្យសុំចេញពីព្រះរាជាណាចក្រកម្ពុជា តាមរយៈស្នងការនគរបាលខេត្ត ក្រុង ។

២-ត្រូវភ្ជាប់មកជាមួយនូវសេចក្តីចម្លងលិខិតឆ្លងដែនរបស់ខ្លួន ឬសេចក្តីចម្លងឯកសារធ្វើដំណើរ ។

៣-ត្រូវផ្តល់លិខិតថតចម្លងប័ណ្ណស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំនួនមួយច្បាប់ ។

៤- រូបថតទំហំ ៤ × ៦ មួយសន្លឹក « ថតចំពីមុខ គ្មានពាក់មួក និង វ៉ែនតាពណ៌ » ។

៥- ត្រូវបង់អាករទិដ្ឋាការចេញ - ចូល មួយលើកចំនួនប្រាំម៉ឺនរៀល (៥០.០០០៛០០ )

កុមារមានអាយុ ១២ឆ្នាំចុះ ធ្វើដំណើរជាមួយឪពុក ម្ដាយ ឬ អាណាព្យាបាលមិនបាច់បំពេញ បែបបទដោយឡែកទេ តែត្រូវចុះឈ្មោះ និង បិទរូបថតជាមួយ ឪពុក ម្ដាយ ឬអាណាព្យាបាល ។ កុមារជាអនីតិជន ដែលធ្វើដំណើរទោលតែឯង ត្រូវបង្ហាញលិខិតអនុញ្ញាតិអោយចេញ ដែលចុះ ហត្ថលេខាដោយអាណាព្យាបាល ឬ ឪពុក ម្ដាយស្រប ច្បាប់របស់គេ ។

**មាត្រា ៩ :** ជនបរទេសអន្តោប្រវេសន្ត ដែលបានបំពេញបែបបទដូចមានចែងក្នុងមាត្រា ៨ ខាងលើ អាចទទួលការបោះត្រា « អនុញ្ញាតអោយចេញ ចូលច្រើនដង » នៅលើលិខិតឆ្លងដែន ឬ ឯកសារធ្វើដំណើរ ។ រយៈពេលនៃការអនុញ្ញាតអោយចេញ ចូលច្រើនដងនោះមិនត្រូវអោយលើសពីបីខែឡើយ ។

អាករទិដ្ឋាការ « អនុញ្ញាតអោយចេញ ចូលច្រើនដងត្រូវកំណត់ » ចំនួនបីសែនរៀល ( ៣០០.០០០ ៛០០ ) ។

**មាត្រា ១០ :** អាករគ្រប់ប្រភេទខាងលើ ត្រូវបង់ចូលថវិកាជាតិ ។

បែបបទនៃការប្រមូលអាករ នេះត្រូវ កំណត់ដោយប្រកាសអន្តរក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ។

## ជំពូកទី៤

## ការដកហូតលក្ខណៈសម្បត្តិជាជនបរទេសអន្តោប្រវេសន្ត

**មាត្រា ១១ :** អាចត្រូវដកហូតលក្ខណៈសម្បត្តិជាជនបរទេសអន្តោប្រវេសន្ត ដោយប្រកាសរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំពោះជនបរទេសអន្តោប្រវេសន្តណាដែលបានប្រព្រឹត្តល្មើស នឹងបទបញ្ញត្តិ នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ហើយដែលត្រូវតុលាការផ្ដន្ទាទោសឧក្រិដ្ឋចាប់ពី៥ឆ្នាំឡើងទៅ ។

## ជំពូកទី៥

## អវសានបញ្ញត្តិ

**មាត្រា ១២ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៣** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន រដ្ឋលេខាធិការមុខងារសាធារណៈ គ្រប់ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ៣១ អនក្រ.បក**

**ស្តីពីការប្តូរឈ្មោះ « សាកលវិទ្យាល័យភ្នំពេញ »**

**មកជា « សាកលវិទ្យាល័យភូមិន្ទភ្នំពេញ »**

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤